# សេចក្តីពន្យល់

## ច្បាប់

### ស្តីពី

## វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ (Law on Covid-19)


បទបង្ហាញៈ លោក រី សុវណ្ណា

ប្រធានផ្នែកគោលនយោបាយ ច្បាប់ និងការតស៊ូមតិ


រាជធានីភ្នំពេញ ថ្ងៃទី 06 ខែ សីហា ឆ្នាំ ២០២១

# ពិន័យអន្តរការណ៍ *វិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩*




ពិន័យអន្តរការណ៍ - ការបំពានវិធានសុខាភិបាលជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល - ការបំពានវិធានការរដ្ឋបាល និងវិធានការផ្សេងៗជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចចេញវិធានការនោះ ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្ដឹងអាជ្ញាចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់ ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
រដ្ឋបាលខេត្តស្វាយរៀង
បង្កាន់ដៃពិន័យអន្តរការណ៍

# សមិទ្ធកម្មនៃច្បាប់កូវីដ

1. ផលជះអវិជ្ជមានធ្ងន់ធ្ងរដល់សុខភាពសាធារណៈ អាយុជីវិតរបស់ប្រជាពលរដ្ឋ និងសណ្តាប់ធ្នាប់សាធារណៈ និងការកាត់បន្ថយជាអតិប្បរមានៃផលប៉ះពាល់នៃការឆ្លងចំពោះវិស័យសង្គម និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា
2. កម្ពុជាត្រូវត្រៀមខ្លួនសម្រាប់រយៈពេលវែង និងជាយថាហេតុដើម្បីឆ្លើយតបទាន់សភាពការណ៍នៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរ ក្រៅពីជំងឺកូវីដ ១៩ ។
3. កង្វះបទដ្ឋានច្បាប់ - អនុក្រឹត្យ ២០១៥ វិធានការបង្ការជំងឺឆ្លងនៅតាមច្រកទ្វារអន្តរជាតិកម្ពុជា - អនុក្រឹត្យស្តីពីវិធានការនៃការធ្វើចត្តាឡីស័ក និងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន ។

# ហេតុអ្វីមិនអនុវត្តច្បាប់គ្រាអាសន្ន?

1. ស្ថានការណ៍ស្ថិតនៅក្រោមការគ្រប់គ្រងបានដោយរដ្ឋាភិបាល ។ ស្ថានភាពនៃការឆ្លងកម្រិតសហគមន៍ចំនួន ០៣ ដង - ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២០ - ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២០ - ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២១
2. នីតិវិធីនៃការប្រកាសដាក់ប្រទេសស្ថិតនៅក្នុងស្ថានភាពអាសន្ន ។ មូលហេតុ - ចិរៈវេលា - វិធានការ
   - អនុលោមភាពនៃមាត្រា ២២ រដ្ឋធម្មនុញ្ញកម្ពុជា
   - ការបន្តស្ថានភាពអាសន្ន & ការបញ្ចប់ស្ថានភាពអាសន្ន
   - វិធានការ - កម្រិតសិទ្ធិដើរហើរ - សិទ្ធិជួបជុំ - ចត្តាឡីស័ក - កម្រិតសកម្មភាពការងារ & មុខរបរ - កំណែន & ជម្លៀសប្រជាពលរដ្ឋ - ការដកហូត គ្រប់គ្រង និងចាត់ចែកទ្រព្យសម្បត្តិ - ការបិទទីតាំង - ការតាមដាន & ឃ្លាំមើលតាមគ្រប់មធ្យោបាយ - កម្រិតការចែកចាយព័ត៌មាន
   - ទោស
   - ការផ្តល់សិទ្ធិអំណាចធំធេងដល់រដ្ឋាភិបាល
3. កាតព្វកិច្ចជូនដំណឹងទៅអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ

# គោលបំណងនៃច្បាប់កូវីដ ១៩

1. ការដាក់ចេញនូវវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់ដទៃទៀត ដើម្បីឆ្លើយតប ប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរ ។
2. សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ
3. ការកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងនៃជំងឺនេះ ចំពោះវិស័យសង្គម និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

# លក្ខណៈពិសេសនៃច្បាប់កូវីដ ១៩

1. ការផ្តល់នូវសិទ្ធិដ៏ធំធេងដល់រាជរដ្ឋាភិបាលក្នុងការដាក់ចេញនូវវិធានការសុខាភិបាល  វិធានការរដ្ឋបាល និងវិធានការចាំបាច់ដើម្បីការពារសុខភាពសាធារណៈ និងការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ
2. ការកំណត់នូវទណ្ឌកម្ម (ទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មព្រហ្មទណ្ឌ)

# វិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩

- វិធានការសុខាភិបាល៖ កូវីដជាជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ ឆ្លងលេខឆ្លង ១២០ លាននាក់ ស្លាប់ ២ លាននាក់
  - ការធ្វើអនាម័យ
  - ការពាក់ម៉ាស
  - ការរក្សាគម្លាតសុវត្ថិភាពសង្គម
  - ការយកសំណាកទៅវិភាគរកមេរោគកូវីដ ១៩
  - ការធ្វើចត្តាឡីស័ក
  - ការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល
  - ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩
  - ការធ្វើសេចក្តីប្រកាសសុខភាព

រដ្ឋាភិបាលអាចប្រគល់សិទ្ធិដល់ក្រសួងសុខាភិបាលដើម្បីដាក់ចេញនូវវិធានការសុខាភិបាលផ្សេងថែមទៀត សំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ឱ្យទាន់ពេលវេលា ។

ខ្លឹមសារលម្អិតនៃវិធានការសុខាភិបាល ត្រូវកំណត់ដោយអនុក្រឹត្យ និងបានប្រគល់សិទ្ធិដល់ក្រសួងសុខាភិបាលដើម្បីដាក់ចេញនូវវិធានការផ្សេងទៀត ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ឱ្យបានទាន់ពេលវេលា ។

# វិធានការរដ្ឋបាលនៃច្បាប់កូវីដ ១៩

- ការរិតត្បិត ឬហាមឃាត់ការធ្វើដំណើរ
- ការជួបជុំ និងការប្រមូលផ្តុំមនុស្ស
- ការកម្រិតការធ្វើសកម្មភាពការងារ ឬមុខរបរ
- ការបិទខ្ទប់តំបន់ ឬទីកន្លែងមួយចំនួនដែលមានការឆ្លង
- ការរឹតត្បឹត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លង

- រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិអំណាចដល់ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដើម្បីដាក់ចេញនូវវិធានការខាងលើ សំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ឱ្យបានទាន់ពេលវេលា ។

# ទណ្ឌកម្ម

- ទណ្ឌកម្មរដ្ឋបាល៖ ការព្យួរ ឬដកហូតអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតិប្រកបអាជីវកម្ម ឬ ការបិទអាជីវកម្ម

- ទណ្ឌកម្មព្រហ្មទណ្ឌ
  - ពិន័យអន្តរការណ៍ - ការបំពានវិធានសុខាភិបាលជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល - ការបំពានវិធានការរដ្ឋបាល និងវិធានការផ្សេងៗជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចចេញវិធានការនោះ ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញាចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់ ។ ករណីខកខានមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ៣០ ថ្ងៃ មន្ត្រីដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌នៃក្រសួងស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។
  - ការពិន័យជាប្រាក់
  - និង ទោសដាក់ពន្ធនាគារ

# នីតិវិធីតវ៉ាចំពោះការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល

- សមត្ថកិច្ច៖ ក្រសួង ស្ថាប័នដែលចេញអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត្តិ
- បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេច៖ អាចប្ដឹងតវ៉ាទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងរយៈពេល ៣០ ថ្ងៃ ។
- ការមិនសុខសចិត្តនឹងសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័ន៖ បុគ្គលអាចដាក់ពាក្យប្ដឹងទៅតុលាការក្នុងរយៈពេល ៦០ ថ្ងៃ ក្រោយទទួលបានសេចក្ដីសម្រេចលើបណ្ដឹងតវ៉ា ។
- ការដាក់ពាក្យប្ដឹងតវ៉ា មិនមានអានុភាពផ្អាកការអនុវត្តសេចក្ដីសម្រេចស្ដីពីការដាក់ទណ្ឌកម្មទេ ។

# បទល្មើស

- បទគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័ក៖ អំពើគេចវេសពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័កដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច ។
- បទគេចវេះពីការព្យាបាល ឬគេចចេញពីទីកន្លែងព្យាបាល៖ គេចវេះពីការតម្រូវឱ្យទទួលការព្យាបាល ឬគេចចេញពីទីកន្លែងព្យាបាលដែលកំណត់ដោយក្រសួងសុខាភិបាល ឬការប៉ុនប៉ងប្រព្រឹត្តិអំពើនេះ ។
- បទចម្លងដោយចេតនានូវជំងឺកូវីដ ១៩ ដល់អ្នកដទៃ៖ អំពើចម្លងដោយចេតនានូវជំងឺកូវីដ ១៩ ដល់អ្នកដទៃ តាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោស ។
- បទមិនគោរពវិធានការរដ្ឋបាល
- បទរារាំងដល់ការអនុវត្តវិធានការ៖អំពើរារាំង ឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការ

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិបុគ្គលដទៃត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តិស្របតាមច្បាប់កម្ពុជា ។

# ករណីលើកលែងឱ្យរួចផុតពី ការទទួលខុសត្រូវ ឬ ការសម្រាលការទទួលខុសត្រូវ

លើកទឹកចិត្តឱ្យបុគ្គល ឬក្រុមគ្រួសារប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬផ្តល់កិច្ចសហការចាំបាច់នានា ដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ឱ្យបានទាន់ពេលវេលា ។

# ចំណោទបញ្ហា

*វិធានការសុខាភិបាល និង វិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩*

# អធិប្បាយ អនុក្រឹត្យ

*វិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត*

# ការចូលរួមរបស់ប្រជាពលរដ្ឋចំពោះវិធានការសុខាភិបាល

- ❖ ការលើកទឹកចិត្តក្នុងការអនុវត្តវិធានការសុខាភិបាលៈ ការធ្វើអនាម័យ ការវាស់កំដៅ ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព

- ❖ សហគ្រាស គ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម និងបុគ្គលគ្រប់រូបត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព នៅតាមទីសាធារណៈ ឬទីកន្លែងដែលមានការជួបជុំមនុស្ស ដើម្បីបង្ការការចម្លង ឬការឆ្លងមេរោគកូវីដ ១៩

# ការពាក់ម៉ាសជាកាតព្វកិច្ច

- ការពាក់ម៉ាសត្រូវធ្វើជាកាតព្វកិច្ចដោយផ្អែកតាមសកម្មភាពការងារ ឬស្ថានភាពមុខរបររបស់បុគ្គល នៅតាមទីកន្លែងដែលមានហានិភ័យ នៃការចម្លង ឬការឆ្លងមេរោគកូវីដ ១៩ ។
- បុគ្គលដែលមានកាតព្វកិច្ចពាក់ម៉ាស និងទីកន្លែងដែលតម្រូវឱ្យមានការពាក់ម៉ាស ត្រូវកំណត់ដោយក្រសួងសុខាភិបាល ដោយផ្អែកលើកម្រិតនៃការឆ្លងរាលដាលនៃជំងឺកូវីដ ១៩

# ការយកសំណាកទៅវិភាគមេរោគកូវីដ ១៩

- ពលរដ្ឋខ្មែរ និងជនបរទេស ដែលធ្វើដំណើរពីបរទេសចូលមកកម្ពុជាតាមគ្រប់មធ្យោបាយ - លិខិតបញ្ជាក់ថាគ្មានកូវីដ ១៩ មានសុពលភាពរយៈពេល ៧២ ម៉ោងមុនពេលចេញដំណើរ
- បុគ្គលដែលមន្ត្រីសុខាភិបាលសង្ស័យថាមានផ្ទុកមេរោគកូវីដ ១៩
- បុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកមានផ្ទុកមេរោគកូវីដ ១៩
- បុគ្គលដែលកំពុងធ្វើចត្តាឡីស័ក

# ការធ្វើចត្តាឡីស័ក

- ពលរដ្ឋខ្មែរ និងជនបរទេស ដែលធ្វើដំណើរពីបរទេសចូលមកកម្ពុជាតាមគ្រប់មធ្យោបាយ -
- បុគ្គលដែលមន្ត្រីសុខាភិបាលសង្ស័យថាមានផ្ទុកមេរោគកូវីដ ១៩
- បុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកមានផ្ទុកមេរោគកូវីដ ១៩
- ការធ្វើចត្តាឡីស័កនៅកន្លែងធ្វើចត្តាឡីស័កណាមួយ ឬនៅលំនៅឋានរបស់បុគ្គល

- កាតព្វកិច្ចនៃការធ្វើចត្តាឡីស័ក៖ ការគោរពតាមបទបញ្ជាផ្ទៃក្នុង - គោរពតាមវិធានការផ្នែកសុខាភិបាល - ការមិនចាកចេញពីកន្លែងធ្វើចត្តាឡីស័កដោយគ្មានការអនុញ្ញាត្តិ - ការសហការ - ការផ្តល់ព័ត៌មាន

# ការទទួលការព្យាបាលចំពោះបុគ្គលមានផ្ទុកមេរោគកូវីដ ១៩

- កាតព្វកិច្ចនៃការព្យាបាល៖ ការគោរពតាមបទបញ្ជាផ្ទៃក្នុង - គោរពតាមវិធានការផ្នែកសុខាភិបាល - ការមិនចាកចេញពីកន្លែងព្យាបាលដោយគ្មានការអនុញ្ញាត្តិ - ការសហការ - ការផ្តល់ព័ត៌មាន - ការយកសំណាកទៅពិនិត្យ

# ការគ្រប់គ្រង និងចាត់ចែងសាកសពមានផ្ទុកមេរោគកូវីដ ១៩

- មិនអនុញ្ញាតិឱ្យគ្រួសារសពជាអ្នកគ្រប់គ្រង និងចាត់ចែងឡើយ
- យកទៅបូជា ឬបញ្ចុះតាមប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនាដោយត្រូវអនុវត្តតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល - ការរៀបចំសាកសព ការដឹកជញ្ជូន ការកម្រិតអ្នកចូលរួមនៅពេលបូជា ឬបញ្ចុះសព
- ការបូជា ឬបញ្ចុះត្រូវធ្វើឱ្យបានឆាប់ដោយគ្មានបង្អង់

# ការចាក់វ៉ាក់សាំងមេរោគកូវីដ ១៩

- ដោយគោលការណ៍ស្ម័គ្រចិត្ត
- ជាកាតព្វកិច្ចចំពោះបុគ្គលមួយចំនួនដោយផ្អែកលើស្ថានភាពការងារ ឬ ស្ថានភាពនៃមុខរបរតាមការកំណត់របស់ក្រសួងសុខាភិបាល
- ការតម្រូវឱ្យជនបរទេសជាអ្នកដំណើរត្រូវមានប័ណ្ណបញ្ជាក់ពីការចាក់វ៉ាក់សាំង

# បទល្មើស

- កាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គល
- ការមិនសហការយកវត្ថុសំណាកទៅវិភាគ
- គេចវេះពីការធ្វើចត្តាឡីស័ក
- ការសម្រួលសម្រួលដោយចេតនាដើម្បីឱ្យគេចចេញពីការធ្វើចត្តាឡីស័ក
- រំលោភវិធានការដាក់ឱ្យនៅដោយឡែកដើម្បីទទួលការព្យាបាល
- មិនបានជូនដំណឹងដល់ក្រសួងសុខាភិបាលដោយគ្រឹះស្ថានសុខាភិបាលឯកជន

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិបុគ្គលដទៃត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តិស្របតាមច្បាប់កម្ពុជា ។

# ករណីលើកលែងឱ្យរួចផុតពី ការទទួលខុសត្រូវ ឬ ការសម្រាលការទទួលខុសត្រូវ

លើកទឹកចិត្តឱ្យបុគ្គល ឬក្រុមគ្រួសារប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬផ្តល់កិច្ចសហការចាំបាច់នានា ដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ឱ្យបានទាន់ពេលវេលា ។

# សូមអរគុណ...